## ភ្លើង និង មេរៀននៃការគោរពប្រតិបត្តិ

ប្រធាន ថូម៉ាស អេស ម៉នសុន បានតំណាលប្រាប់ពីគ្រាមួយ កាលលោកបានរៀនពីសារៈសំខាន់នៃការគោរពប្រតិបត្តិ ។ កាលលោកអាយុប្រាំបីឆ្នាំ ក្រុមគ្រួសាររបស់លោកបានទៅលេងផ្ទះឈើសម្រាប់លំហែរបស់ពួកលោកនៅឯតំបន់ភ្នំ ។ លោក និង មិត្តភក្តិរបស់លោកម្នាក់ចង់សម្អាតវាលមួយដែលមានសុទ្ធតែស្មៅសម្រាប់ធ្វើជាកន្លែងដុតភ្លើងបោះជំរុំ ។ ពួកលោកបានព្យាយាមសម្អាតស្មៅនោះដោយប្រើដៃ ដោយដក និង កន្ត្រាក់វាខ្លាំងៗតាមកម្លាំងរបស់ពួកលោក ប៉ុន្តែពួកលោកគ្រាន់តែអាចដកបានស្មៅពេញៗក្ដាប់ដៃប៉ុណ្ណោះ ។ ប្រធាន ម៉នសុន បានពន្យល់ថា « ហើយអ្វីដែលខ្ញុំបានគិតគឺជាដំណោះស្រាយយ៉ាងល្អ ដែលវាបានផុសឡើងក្នុងគំនិតរបស់ក្មេងអាយុប្រាំបីឆ្នាំដូចរូបខ្ញុំនេះ ។ ខ្ញុំបាននិយាយទៅ ដានី ថា ‹ អ្វីដែលយើងត្រូវធ្វើគឺដុតស្មៅនេះចោល ។ យើងគ្រាន់តែ *ដុត* ស្មៅនោះជារង្វង់ប៉ុណ្ណោះ ! › »

ទោះបីលោកបានដឹងថា លោកពុំត្រូវបានអនុញ្ញាតឲ្យប្រើឈើគូសក្ដី លោកបានរត់ត្រឡប់ទៅក្នុងផ្ទះវិញដើម្បីយកឈើគូសមួយចំនួនមក ហើយលោក និង ដានីបានបង្កាត់ភ្លើងបន្តិចដុតស្មៅនៅតំបន់នោះ ។ ពួកលោករំពឹងថាភ្លើងនោះនឹងរលត់វិញដោយខ្លួនវា ប៉ុន្តែផ្ទុយទៅវិញវាឆេះកាន់តែខ្លាំងឡើង ហើយមានគ្រោះថ្នាក់ ។ លោក និង ដានីបានរត់ទៅរកជំនួយ ហើយរំពេចនោះមនុស្សពេញវ័យបានប្រញាប់ប្រញាល់រត់មកពន្លត់ភ្លើងពីមុនឆេះដល់ដើមឈើទាំងឡាយ ។

ប្រធាន ម៉នសុន បានបន្តទៀតថា « ដានី និង ខ្ញុំបានរៀនមេរៀនពិបាកៗមួយចំនួន ប៉ុន្តែជាមេរៀនដ៏សំខាន់នាថ្ងៃនោះ—ផ្នែកដែលសំខាន់គឺសារៈសំខាន់នៃការគោរពប្រតិបត្តិ » ។ ( សូមមើល « Obedience Brings Blessings » *Liahona* ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៨៩–៩០ ) ។

ដូចប្រធាន ម៉នសុន ដែរ តើអ្នកធ្លាប់បានរៀនមេរៀនមួយនៅក្នុងការគោរពប្រតិបត្តិតាមរបៀបមួយដ៏លំបាកដែរឬទេ ? តើមានគោលដៅណាខ្លះដែលអ្នកអាចធ្វើ ដើម្បីរក្សាខ្លួនអ្នកឲ្យមានសុវត្ថិភាព តាមរយៈការគោរពប្រតិបត្តិនាពេលអនាគតនោះ ?



## ជ្រើសរើសផ្លូវត្រូវ

ការជ្រើសរើសផ្លូវត្រូវជួយនាំយើង ឲ្យខិតកាន់តែជិតព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ វាក៏ជួយយើងឲ្យមានភាពរីករាយ និង សុវត្ថិភាពផងដែរ ។ សូមគូសរង្វង់លើរបៀបនានាដែលអ្នកអាចជ្រើសរើសផ្លូវត្រូវ ។


ទៅព្រះវិហារ


លួចចម្លងនៅសាលារៀន


អានព្រះគម្ពីរ


បម្រើអ្នកដទៃ


លេងល្បែងល្អៗ


ឈ្លោះជាមួយបងប្អូនរបស់អ្នក

រចនារូបភាពដោយ ខាធី ម៉ាក់ឌី